# បណ្តឹងសាទុក្ខក្នុងបណ្តឹងរដ្ឋប្បវេណី



*December 2, 2018*
*Seminar by Contribution of Law*

*UCHIYAMA Jun*

*※មាត្រាដែលមានកំណត់ក្នុងអត្ថបទ គឺយោងក្រមនីតិវិធីរដ្ឋប្បវេណី លើកលែងតែមានសរសេរផ្សេង*

# 1 ប្រភេទនៃបណ្តឹងសាទុក្ខ

【ប្រភេទនៃបណ្តឹងសាទុក្ខ】

1 បណ្តឹងសាទុក្ខទូទៅ (ម.283 ក.1)

2 បណ្តឹងសាទុក្ខផ្លោះ (ម.283 ក.2, ម.260 ក.1 ចំ.ក, ក.2)

3 បណ្តឹងសាទុក្ខបន្ទាប់បន្សំ (ម.286･ម.270)

# 【លំហូរនៃបណ្ដឹងសាទុក្ខ】



# បណ្តឹងសាទុក្ខផ្លោះ

(ម.283 ក.2, ម.260 ក.1 ចំ.ក, ក.2)

មាត្រា 283

2 ចំពោះសាលក្រមចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី១ ដោយសាលាដំបូង នៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍នៅក្រោយពេលដែលតុលាការបានចេញសាលក្រមនោះ ដោយរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខ បណ្តឹងសាទុក្ខអាចធ្វើទៅតុលាការកំពូលដោយផ្ទាល់បាន។

មាត្រា 260

1 បណ្តឹងឧទ្ធរណ៍អាចធ្វើចំពោះសាលក្រមចុងក្រោយរបស់សាលាដំបូងបាន លើកលែងតែករណីដែលបានកំណត់ខាងក្រោមនេះ ៖

ក គូភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ ដោយរក្សាទុកសិទ្ធិប្តឹងសាទុក្ខ ក្រោយពេលតុលាការ បានចេញសាលក្រមចុងក្រោយ។

2 សេចក្តីព្រមព្រៀងដែលបានកំណត់ក្នុងចំណុច ក នៃកថាខណ្ឌទី១ ខាងលើនេះ ពុំមានអានុភាពឡើយ ប្រសិនបើមិនបានធ្វើលិខិតជាលាយល័ក្ខណ៍អក្សរ។

# បណ្ដឹងសាទុក្ខផ្លោះ

(ម.283 ក.2, ម.260 ក.1 ចំ.ក, ក.2)

**[ចំណុចគួរប្រយ័ត្ន]**

- ព្រមព្រៀងជា「លាយលក្ខណ៍អក្សរ」នៅ「ក្រោយពេល」តុលាការចេញសាលក្រមចុងក្រោយ។
- 「គូ」ភាគីរក្សាទុកនូវសិទ្ធិប្ដឹងសាទុក្ខ។
- ភាគីទាំងសងខាងមិនមានវិវាទអំពីការទទួលស្គាល់អង្គហេតុនៅក្នុងសាលក្រមជំនុំជម្រះលើកទី១។
- ទាមទារឲ្យសម្រេចក្នុងការវិនិច្ឆ័យបណ្ដឹងសាទុក្ខអំពីបញ្ហាផ្លូវច្បាប់ដោយរំលងការវិនិច្ឆ័យបណ្ដឹងឧទ្ធរណ៍។
- ចំណុចដែលអាចស្រាវជ្រាវដោយឆន្ទានុសិទ្ធិចំពោះការវិនិច្ឆ័យបណ្ដឹងសាទុក្ខ (យោង ម.297)។

# ការព្រមព្រៀងផ្ដោះបណ្ដឹងសាទុក្ខ(២)

## លិខិតព្រមព្រៀង

ដើមចោទ　○○○(អាសយដ្ឋាន)

X (ឈ្មោះ)

ចុងចម្លើយ　□□□(អាសយដ្ឋាន)

Y (ឈ្មោះ)

ដើមចោទ និង ចុងចម្លើយទាំងសងខាងបានព្រមព្រៀងគ្នាមិនប្ដឹងឧទ្ធរណ៍ចំពោះសាលក្រមជំនុំជម្រះលើកទី១ នៃរឿងក្ដី (លេខរឿងក្ដី) របស់សាលាដំបូង △△ រវាងដើមចោទ និង ចុងចម្លើយខាងលើ។ ប៉ុន្តែ សិទ្ធិប្ដឹងសាទុក្ខត្រូវរក្សាទុកសម្រាប់ភាគីទាំងសងខាង។

# បណ្ដឹងសាទុក្ខបន្ទាប់បន្សំ

(ម.286-ម.270)

មាត្រា286

បញ្ញត្តិនៃជំពូកទី២ នៃគន្ថីទី៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្ដឹងសាទុក្ខ និង នីតិវិធីនៃការជំនុំជម្រះបណ្ដឹងសាទុក្ខ លើកលែងតែមានបញ្ញត្តិពិសេស។

*ជំពូកនៃ「បណ្ដឹងឧទ្ធរណ៍」

មាត្រា270 *

1 ចុងបណ្ដឹងឧទ្ធរណ៍ ទោះបីជាសិទ្ធិប្ដឹងឧទ្ធរណ៍នោះត្រូវបានរលត់ហើយក៏ដោយ ក៏អាចប្ដឹងឧទ្ធរណ៍បន្ទាប់បន្សំបានដែរ រហូតដល់ពេលដែលការទាញហេតុផលផ្ទាល់មាត់ ត្រូវបានបញ្ចប់។

2 បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំត្រូវអស់អានុភាព នៅក្នុងករណីដែលពាក្យបណ្ដឹងឧទ្ធរណ៍ ត្រូវបានដក ឬ នៅក្នុងករណីដែលបណ្ដឹងឧទ្ធរណ៍នោះ ត្រូវបានលើកចោលដោយសារមានភាពផ្ទុយនឹងច្បាប់។ ប៉ុន្តែ ចំពោះបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំដែលមានលក្ខខណ្ឌនៃបណ្ដឹងឧទ្ធរណ៍គ្រប់គ្រាន់ ត្រូវចាត់ទុកថាជាបណ្ដឹងឧទ្ធរណ៍ឯករាជ្យ។

3 បញ្ញត្តិស្ដីពីបណ្ដឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ។

*អានដោយជំនួសពាក្យថា បណ្ដឹងឧទ្ធរណ៍ ទៅជា បណ្ដឹងសាទុក្ខ។

# បណ្តឹងសាទុក្ខបន្ទាប់បន្សំ

(ម.286・ម.270)

**【 ចំណុចត្រូវប្រយ័ត្ន】**

- អាចប្តឹងសាទុក្ខបន្ទាប់បន្សំបាន ទោះបីជាបណ្តឹងសាទុក្ខនោះត្រូវបានរលត់ហើយក៏ដោយ។
- 「លក្ខខណ្ឌនៃបណ្តឹងឧទ្ធរណ៍គ្រប់គ្រាន់」សំដៅទៅលើករណីដូចជាអំឡុងពេលបណ្តឹងសាទុក្ខបានបំពេញ ជាដើម។

# 2 ការប្រើឧសាទុក្ខ

【អំឡុងពេលប្តឹងសាទុក្ខ】(ម.286 , ម.264)

អំឡុងពេល ១ខែ ដោយគិតចាប់តាំងពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម។



【របៀបប្ដឹងសាទុក្ខ】(ម.287)

ដាក់ពាក្យបណ្ដឹងសាទុក្ខទៅតុលាការដើម។

តុលាការដើមត្រូវផ្ញើពាក្យបណ្ដឹងសាទុក្ខ និង សំណុំរឿងទៅតុលាការនៃបណ្ដឹងសាទុក្ខ។

【ការពិនិត្យពាក្យបណ្ដឹងសាទុក្ខ】(ម.286, ម.266)

តុលាការនៃបណ្ដឹងសាទុក្ខទទួលបន្ទុក។

*ពិនិត្យ*

*ដាក់*



*ផ្ញើ*




ពាក្យបណ្ដឹងសាទុក្ខ

តុលាការដើម

តុលាការនៃបណ្ដឹងសាទុក្ខ

# 3 ពាក្យបណ្តឹងសាទុក្ខ

【ចំណុចចាំបាច់ត្រូវសរសេរ】(ម.286, ម.265 ក.2)

ក: ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី,
ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដោយច្បាប់បានកំណត់

ខ:① សញ្ញាណនៃសាលដីកាសាលាឧទ្ធរណ៍
→បញ្ជាក់ដោយឈ្មោះរបស់ភាគី និង លេខរឿងក្ដីជាអាទិ៍។
② ការប្ដឹងសាទុក្ខចំពោះសាលដីកាខាងលើ
→នៅក្នុងពាក្យបណ្ដឹងសាទុក្ខ ចំណុចដែលត្រូវគ្នានឹង
「ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យ
តុលាការចេញ」ក្នុងពាក្យបណ្ដឹង មិនមែនជាចំណុច
ចាំបាច់ត្រូវសរសេរនោះទេ។

【ចំណុចដែលគួរតែសរសេរ】

ហេតុជាក់ស្តែងដែលដើមបណ្តឹងទាមទារឲ្យលុបចោល ឬ កែប្រែសាលក្រមដើម(មូលហេតុនៃបណ្តឹងសាទុក្ខ)

→ប្រសិនបើមិនបានសរសេរនូវមូលហេតុនៃបណ្តឹងសាទុក្ខក្នុងពាក្យបណ្តឹងសាទុក្ខទេ ដើមបណ្តឹងអាចសរសេរក្នុងលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខនេះ ពេលក្រោយបាន (យោង ម.289 ក.1)។

# ពាក្យបណ្ដឹងសាទុក្ខ(៤)

## ពាក្យបណ្ដឹងសាទុក្ខ

【ភាគី】

ដើមបណ្ដឹងសាទុក្ខ ○○○(អាសយដ្ឋាន)
X(ឈ្មោះ)

ចុងបណ្ដឹងសាទុក្ខ □□□(អាសយដ្ឋាន)
Y(ឈ្មោះ)

# ពាក្យបណ្ដឹងសាទុក្ខ(ឧ · បន្ត)

【 ការប្ដឹងសាទុក្ខចំពោះសាលដីកាសាលាឧទ្ធរណ៍】
ប្ដឹងសាទុក្ខមិនសុខចិត្តនឹងសាលដីកាដែលសាលាឧទ្ធរណ៍បានប្រកាសនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ អំពីរឿងក្ដី (លេខរឿងក្ដី ) របស់សាលាឧទ្ធរណ៍ភ្នំពេញរវាងដើមបណ្ដឹងសាទុក្ខ និង ចុងបណ្ដឹងសាទុក្ខ។

【សញ្ញាណនៃសាលដីកាសាលាឧទ្ធរណ៍】

ច្រានចោលបណ្ដឹងឧទ្ធរណ៍។

ប្រាក់ប្រដាប់ក្ដីនៃបណ្ដឹងឧទ្ធរណ៍ជាបន្ទុករបស់ដើមបណ្ដឹងឧទ្ធរណ៍។

# ពាក្យបណ្ដឹងសាទុក្ខ(២ · បន្ត)

【 ខ្លឹមសារនៃសាលក្រមដែលដើមបោទទាមទារឲ្យតុលាការចេញ 】
ទាមទារឲ្យប្រោនចោលសាលដីកាដើម និង វិនិច្ឆ័យឲ្យត្រឹមត្រូវ។

【 មូលហេតុនៃបណ្ដឹងសាទុក្ខ】
លិខិតបញ្ជាក់អំពីមូលហេតុដាក់ជូនពេលក្រោយ។

# 4 ការទទួលពាក្យបណ្តឹងសាទុក្ខ

【ករណីពាក្យបណ្តឹងសាទុក្ខគ្មានចំណុចខ្វះខាត】

តុលាការត្រូវបញ្ជូនលិខិតទទួលពាក្យបណ្តឹងសាទុក្ខ និង ពាក្យបណ្តឹងសាទុក្ខទៅភាគី (ម.288)។

→តុលាការចេញដីកាសម្រេចលើកចោលពាក្យបណ្តឹងសាទុក្ខ ប្រសិនបើមិនអាចបញ្ជូនបាន (ម.286･ម.273･ម.79 ក.2･ម.78)។

ដីកាសម្រេចនេះ មិនអាចប្តឹងជំទាស់បានទេ ពីព្រោះគ្មានតុលាការដែលមានឋានានុក្រមខ្ពស់ជាងតុលាការនៃបណ្តឹងសាទុក្ខឡើយ។

【 ករណីពាក្យបណ្ដឹងសាទុក្ខមានចំណុចខ្វះខាត 】

- ខ្វះចំណុចចាំបាច់ដែលត្រូវសរសេរ(ម.286・ម.265)
- មិនបានដាក់លិខិតមូលហេតុនៃបណ្ដឹងសាទុក្ខ(ម.289 ក.1)
- ខ្វះមូលហេតុនៃបណ្ដឹងសាទុក្ខ(ម.289 ក.2 ,ក.3)

→បង្គាប់ឲ្យកែតម្រូវ (ម.286・ម.266 ក.1)

→ដីកាសម្រេចលើកចោលពាក្យបណ្ដឹងសាទុក្ខ បើសិនជាក្រោយបង្គាប់ឲ្យកែតម្រូវ ហើយមិនអាចកែតម្រូវចំណុចខ្វះខាតបាន ( ម.286・ម.266 ក.2)

# 5 លក្ខខណ្ឌនៃបណ្ដឹងសាទុក្ខ

【ឧទាហរណ៍ជាក់ស្ដែង】

1) សាលក្រម ឬ សាលដីកាដើមដែលអាចប្ដឹងសាទុក្ខ

- × សាលក្រមរបៀប (ម.181)
  - →ម.283 ក.1「ចំពោះសាលដីកាចុងក្រោយ」។
- × ដីកាសម្រេចមុនសាលក្រម ឬ សាលដីកាចុងក្រោយ
  - *(ឧ)* លើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់ទៅតុលាការយឺតយ៉ាវ (ម.94)
  - →ម.283 ក.1「ចំពោះសាលដីកាចុងក្រោយ」។
- × ផ្នែកដែលខកខានវិនិច្ឆ័យ (ម.183)
  - →ត្រូវបន្ថែមហើយធ្វើជាសាលក្រមចុងក្រោយ។
- × លើតែផ្នែកដែលសម្រេចអំពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី (ម.286・ម.261)
  - →ការទាមទារបន្ទាប់បន្សំក្នុងអង្គសេចក្ដី។

2) ពាក្យបណ្ដឹងសាទុក្ខ និង លិខិតបញ្ជាក់មូលហេតុនៃបណ្ដឹងសាទុក្ខ ត្រូវរៀបចំតាមទម្រង់ដែលច្បាប់កំណត់ និង ដាក់ទៅតុលាការនៃបណ្ដឹងសាទុក្ខឲ្យបានក្នុងអំឡុងពេលកំណត់

- × លិខិតបញ្ជាក់មូលហេតុនៃបណ្ដឹងសាទុក្ខមិនត្រូវផ្ទុយនឹង ម.289 ក.2 ក.3

3) ការបញ្ជូនពាក្យបណ្ដឹងសាទុក្ខជាអាទិ៍ ដោយមានអានុភាព

- × ការបញ្ជូនមិនផ្ទុយនឹង ម.288

4) ដើមបណ្ដឹងសាទុក្ខមានការមិនសុខចិត្តនឹងសាលក្រម ឬ សាលដីកាដើម

- × ការធ្វើបណ្ដឹងសាទុក្ខដោយភាគីដែលឈ្នះក្ដីទាំងស្រុងក្នុងសាលាឧទ្ធរណ៍

5) ដើមបណ្ដឹងសាទុក្ខមិនបានបោះបង់ចោលសិទ្ធិប្ដឹងសាទុក្ខ (ម.286・ម.263 ក.1) ឬ មិនបានព្រមព្រៀងមិនឲ្យធ្វើបណ្ដឹងសាទុក្ខ

6) មិនដាក់បណ្ដឹងសាទុក្ខជាន់គ្នា

7) មិនបានប្រើប្រាស់សិទ្ធិប្ដឹងសាទុក្ខដោយបំពាន

- × ធ្វើបណ្ដឹងសាទុក្ខក្នុងគោលបំណងតែពន្យារពេលសាលក្រមមិនឲ្យចូលស្ថាពរ

8) លក្ខខណ្ឌនៃបណ្ដឹងទូទៅ (សមត្ថភាពរបស់ភាគី ជាអាទិ៍) គ្រប់គ្រាន់

【ករណីខ្វះលក្ខខណ្ឌនៃបណ្តឹងសាទុក្ខ】

តុលាការចេញដីកាសម្រេចលើកចោលបណ្តឹងសាទុក្ខ ក្នុងករណីបណ្តឹងសាទុក្ខនោះខុសច្បាប់ ហើយមិនអាចកែតម្រូវបាន (ម.290 ចំ. ក)។

→មិនចាំបាច់បើកការទាញហេតុផលផ្ទាល់មាត់ ដោយសារតែវាជានីតិវិធីនៃដីកាសម្រេច (ម.286・ម.273・ម.114 ក.1 វ.2)។

# 6 លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខ

【កំណត់ពេលដាក់】(ម.289 ក.1)

ប្រសិនបើមិនបានសេរសេរនូវមូលហេតុនៃបណ្តឹងសាទុក្ខក្នុងពាក្យបណ្តឹងទេ ដើមបណ្តឹងសាទុក្ខត្រូវដាក់លិខិតនោះ ក្នុងអំឡុងពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតទទួលពាក្យបណ្តឹងសាទុក្ខ(ម.289 ក.1)។



【កន្លែងត្រូវដាក់】(ម.289 ក.1)

តុលាការនៃបណ្ដឹងសាទុក្ខ

【ខ្លឹមសារដែលត្រូវសរសេរ】(ម.289 ក.2 , ក.3)

1) ករណីមូលហេតុទូទៅនៃបណ្ដឹងសាទុក្ខ (ម.284)

- បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ច្បាប់ ឬ បទដ្ឋានគតិយុត្ត, ហេតុដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬ បទដ្ឋានគតិយុត្តនោះ។
- ប្រសិនបើ ហេតុនោះមានទំនាក់ទំនងនឹងនីតិវិធីនៃបណ្ដឹង ត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់នូវអង្គហេតុដែលផ្ទុយនោះ។

2) ករណីមូលហេតុដែលត្រូវធ្វើបណ្ដឹងសាទុក្ខ (ម.285)

- ចំណុចដែលជាមូលហេតុដែលត្រូវតែធ្វើបណ្ដឹងសាទុក្ខជាដរាប, ហេតុដែលត្រូវនឹងចំណុចនោះ។

【ករណីដែលមិនដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្ដឹងសាទុក្ខ】

ដីកាសម្រេចលើកចោលបណ្ដឹងសាទុក្ខ(ម.290 ចំ.ខ)

【ករណីលិខិតបញ្ជាក់មូលហេតុនៃបណ្ដឹងសាទុក្ខមានភាពខ្វះខាត】

បង្គាប់ឲ្យកែតម្រូវ(ម.291 ក.1)

→ ដីកាសម្រេចលើកចោលបណ្ដឹងសាទុក្ខ ប្រសិនបើមិនកែតម្រូវ (ម.291 ក.2 និង ម.290 ចំ.ខ)

【ករណីលិខិតបញ្ជាក់មូលហេតុនៃបណ្ដឹងសាទុក្ខត្រូវបានដាក់ ហើយគ្មានភាពខ្វះខាត】

បញ្ជូនឯកសារចម្លងទៅចុងបណ្ដឹងសាទុក្ខ (ម.292 វ.1)

→ប៉ុន្តែ ការបញ្ជូនមិនតម្រូវឲ្យធ្វើឡើយ ប្រសិនបើតុលាការមិនបើកការទាញហេតុផលផ្ទាល់មាត់ (ម.292 វ.2)

# លិខិតបញ្ជាក់មូលហេតុនៃបណ្ដឹងសាទុក្ខ (२)

## លិខិតបញ្ជាក់មូលហេតុនៃបណ្ដឹងសាទុក្ខ

【ភាគី】

| | |
|---|---|
| ដើមបណ្ដឹងសាទុក្ខ | ○○○(អាសយដ្ឋាន) |
| | X(ឈ្មោះ) |
| ចុងបណ្ដឹងសាទុក្ខ | □□□(អាសយដ្ឋាន) |
| | Y(ឈ្មោះ) |

ដើមបណ្ដឹងសាទុក្ខសូមដាក់មូលហេតុនៃ បណ្ដឹងសាទុក្ខ ចំពោះរឿងក្ដី(លេខរឿងក្ដី)របស់សាលាឧទ្ធរណ៍ភ្នំពេញរវាងដើមបណ្ដឹងសាទុក្ខ និង ចុងបណ្ដឹងសាទុក្ខ ដូចខាងក្រោម ៖

# លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខ (៤ · បន្ត )

【មូលហេតុនៃបណ្តឹងសាទុក្ខ】

1 នៅក្នុងសាលដីកាដើមនេះមានកំហុសក្នុងការអនុវត្ត / បកស្រាយរដ្ឋធម្មនុញ្ញដែលនាំឲ្យមានឥទ្ធិពលដល់សាលដីកាដូចខាងក្រោម ( ម.284)។

‥‥(សរសេរចំណុចជាក់ស្តែងអំពីមាត្រា និង ហេតុផ្សេងៗ)

2 នៅក្នុងសាលដីកាដើមនេះមានភាពផ្ទុយនឹងច្បាប់ ដោយការចូលរួមរបស់ចៅក្រមដែលមិនអាចចូលរួមបានក្នុងសាលក្រមនេះតាមផ្លូវច្បាប់ (ម.285 ក.1 ចំ.២ )

‥‥(សរសេរចំណុចជាក់ស្តែងអំពីមាត្រា និង ហេតុផ្សេងៗ)

អាស្រ័យហេតុនេះ សាលដីកាដើមនេះ ត្រូវតែច្រានចោល ដោយមូលហេតុផ្ទុយនឹងរដ្ឋធម្មនុញ្ញ / ច្បាប់ ឬ បទដ្ឋានគតិយុត្តដែលមានឥទ្ធិពលដល់សាលដីកានេះ។

# 7 មូលហេតុនៃបណ្តឹងសាទុក្ខ

## 【មូលហេតុនៃបណ្តឹងសាទុក្ខ】

1 មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ(ម.284)

2 មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ(ម.285 ក.1)

【 មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ 】(ម.284)

ករណីដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬ បទដ្ឋានគតិយុត្តដែលមានឥទ្ធិពលដល់សាលដីកា ឬ សាលក្រម

- 「ផ្ទុយរដ្ឋធម្មនុញ្ញ」 គឺជា?
  - ○ ករណីបទដ្ឋានគតិយុត្តដែលយកមកអនុវត្តជាដើម គឺមោឃភាពដោយផ្ទុយនឹងរដ្ឋធម្មនុញ្ញ ប៉ុន្តែគេបកស្រាយថាមានអានុភាព ហើយបានយកមកអនុវត្ត
  - ○ ករណីបទដ្ឋានគតិយុត្តមានអានុភាពដោយស្របរដ្ឋធម្មនុញ្ញ ប៉ុន្តែគេបកស្រាយថាមោឃភាព ហើយមិនបានយកមកអនុវត្ត
  - × ករណីមិនបានអះអាងអំពីអធម្មនុញ្ញភាពនៃបទបញ្ញត្តិច្បាប់ដែលយកមកអនុវត្តនៅក្នុងសាលដីកាដើម
    - (※) ករណីដែលអះអាងអំពីអធម្មនុញ្ញភាពនៃមាត្រាដែលគ្មានការពាក់ព័ន្ធដោយផ្ទាល់ជាមួយរឿងក្តី នៅក្នុងច្បាប់តែមួយ។

- «ផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្ត» គឺជា ?
  - ករណីមានកំហុសក្នុងការបកស្រាយច្បាប់ ឬ បទដ្ឋានគតិយុត្ត
  - ករណីមានកំហុសក្នុងការអនុវត្តច្បាប់ ឬ បទដ្ឋានគតិយុត្ត
  - ករណីមាននីតិវិធីដែលផ្ទុយនឹងបញ្ញត្តិច្បាប់នីតិវិធី

- 「មានឥទ្ធិពលដល់សាលក្រម ឬ សាលដីកា」 គឺជា ?
  - ○ ករណីដែលមានលទ្ធភាពជាក់លាក់ខ្លាំងថា សេចក្តីសម្រេចក្នុងសាលដីកាដើមនឹងអាចប្រែប្រួល ប្រសិនបើមិនមានភាពផ្ទុយរដ្ឋធម្មនុញ្ញ ច្បាប់ ឬ បទដ្ឋានគតិយុត្ត
  - × ករណីដែលមានលទ្ធភាពតិចតួចដែលអាចមានឥទ្ធិពលដល់សេចក្តីសម្រេចក្នុងសាលដីកាដើម
  - × ករណីដែលសេចក្តីសម្រេចនៅតែដដែល បើទោះបីជាមិនប្រើប្រាស់ច្បាប់ ឬ បទដ្ឋានគតិយុត្តនោះ ហើយប្រើប្រាស់តាមទ្រឹស្តីផ្សេងក៏ដោយ។

【មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ】(ម.285 ក.1)

ក្នុងករណីដាក់លាក់ណាមួយ ត្រូវចាត់ទុកថា មានមូលហេតុនៃបណ្តឹងសាទុក្ខជាដរាប។

- ទោះបីជាគ្មានឥទ្ធិពលដល់សាលដីកា ឬ សាលក្រមក៏បានដែរ ពីព្រោះច្បាប់ប្រើពាក្យថា「ដរាប」។

1) តុលាការដែលចេញសាលដីកា ឬ សាលក្រម មិនត្រូវបានចាត់តាំងដោយស្របតាមច្បាប់(ម.285 ក.1 ចំ.ក)

*(ឧទាហរណ៍)*

- ចៅក្រម 2 នាក់ចេញសាលក្រម ដែលត្រូវធ្វើដោយក្រុមប្រឹក្សាជំនុំជម្រះ 3នាក់ (យោង ម.23 ក.3)
- សាលក្រមដែលចេញដោយបុគ្គលដែលគ្មានលក្ខណៈសម្បត្តិជាចៅក្រម
- សាលក្រមដែលចេញដោយចៅក្រម ដែលមិនមែនជាចៅក្រមនៅពេលបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ (យោងម.185 ក.1)

2) ចៅក្រមដែលច្បាប់មិនអនុញ្ញាតឲ្យចូលរួមក្នុងការចេញសាលដីកា ឬ សាលក្រម តែបានចូលរួម (ម.285 ក.1 ចំ.ខ)

*(ឧទាហរណ៍)*

- ចៅក្រមដែលបានវិនិច្ឆ័យ និង ចេញសាលដីកា ឬ សាលក្រម ទោះបីជាមានហេតុនៃការដកហូតចៅក្រមក៏ដោយ(ម.27)។
  - សហព័ទ្ធរបស់ចៅក្រមជាភាគីក្នុងរឿងក្ដី(ម.27 ក.1 ចំ.ក)
  - ចៅក្រម និង ដើមចោទធ្លាប់មានរឿងក្ដីពីមុនមក(ម.27 ក.1 ចំ.ឃ)
- ករណីដែលតុលាការនៃបណ្ដឹងសាទុក្ខបានបដិសេធចោល ហើយបញ្ជូនត្រឡប់ទៅតុលាការដើមវិញ ហើយចៅក្រមដែលចូលរួមក្នុងសាលក្រមដើម បានវិនិច្ឆ័យ និងសម្រេច(ម.299 ក.3)។

3) ភាពផ្ទុយនឹងបញ្ញត្តិស្ដីពីសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការ(ម.285 ក.1 ចំ.គ)

*(ឧទាហរណ៍)*

- ពាក្យបណ្ដឹងលែងលះបានដាក់ទៅសាលាដំបូងខុសពីសាលាដំបូងដែលមានសមត្ថកិច្ចនៅទីលំនៅរបស់ភាគី (ម.10 ក.1)។

4) ការខ្វះសិទ្ធិតំណាងដែលកំណត់ដោយច្បាប់ សិទ្ធិតំណាងដោយអាណត្តិ ឬ ប្រគល់សិទ្ធិចាំបាច់សម្រាប់អ្នកតំណាងដើម្បីធ្វើសកម្មភាពបណ្ដឹង(ម.285 ក.1 ចំ.ឃ)

*(ឧទាហរណ៍)*

- បានធ្វើសកម្មភាពក្នុងនាមជាអ្នកអាណាព្យាបាលទូទៅ ទាំងខ្លួនមិនមែនជាអ្នកអាណាព្យាបាលទូទៅ។
- មេធាវីដែលមិនបានទទួលការប្រគល់សិទ្ធិ បានធ្វើសកម្មភាពបណ្ដឹង។
- បុគ្គលដែលគ្មានសិទ្ធិតំណាង បានតំណាងឲ្យនីតិបុគ្គល ហើយធ្វើសកម្មភាពបណ្ដឹង។

លើកលែងតែ(ម.285 ក.2) ករណីមានការទទួលស្គាល់(ម.35 ក.2 , ម.57 ក.3)។

5) ភាពផ្ទុយនឹងបញ្ញត្តិស្តីពីការទាញហេតុផលផ្ទាល់មាត់ជាសាធារណៈ (ម.285 ក.1 ចំ.ង)

*(ឧទាហរណ៍)*

- ការទាញហេតុផលដោយផ្ទាល់មាត់មិនបានធ្វើនៅសាលសវនការជាសាធារណៈ ទាំងគ្មានការព្រួយបារម្ភអំពីការប៉ះពាល់ដល់សណ្តាប់សាធារណៈទាល់តែសោះ (ម.115 ក.2)។

6) សាលដីកា ឬ សាលក្រម គ្មានសំអាងហេតុ ឬ មានសំអាងហេតុ តែផ្ទុយគ្នា (ម.285 ក.1 ចំ.ច)

*(ឧទាហរណ៍)*

- ខ្លឹមសារដែលសរសេរក្នុងសំអាងហេតុ ផ្ទុយគ្នានឹងចំនួនទឹកប្រាក់ដែលត្រូវបង្គាប់ឲ្យបង់។

・「គ្មានសំអាងហេតុ」គឺជាសំអាងហេតុដែលខ្វះខាតទាំងស្រុង ឬ មួយផ្នែក ដើម្បីឈានដល់ការចេញសេចក្ដីសម្រេចបញ្ចប់។

・「មានសំអាងហេតុតែផ្ទុយគ្នា」គឺជា សំអាងហេតុដែលសរសេរខ្លឹមសារមុនក្រោយផ្ទុយគ្នា ចំពោះចំណុចសំខាន់ដែលមានឥទ្ធិពលខ្លាំងដល់សាលក្រម ឬ សាលដីកា។

*Q តើយើងអាចដាក់បណ្តឹងសាទុក្ខ ដោយមូលហេតុគ្រាន់តែ「មិនអាចទទួលយកសេចក្តីសម្រេចក្នុងសាលក្រម ឬ សាលដីកាដើមបាន」ឬ「សេចក្តីសម្រេចក្នុងសាលក្រម ឬ សាលដីកាដើមមិនយុត្តិធម៌」បានដែរឬទេ?*

A មិនបានទេ។

ដោយសារតែមិនមានសរសេរដាក់ស្តែងអំពីមូលហេតុនៃបណ្តឹងសាទុក្ខ តុលាការចេញដោយការសម្រេចលើកចោល តាម ម.290 ចំ.ខ។

# ៨ ការវិនិច្ឆ័យនៃការជំនុំជម្រះ បណ្ដឹងសាទុក្ខ

【សារធាតុនៃការជំនុំជម្រះបណ្ដឹងសាទុក្ខ】

1 ការជំនុំជម្រះតាមក្រោយ (ម.296 ក.1)

- 「ការជំនុំជម្រះតាមក្រោយ」 គឺជា ប្រព័ន្ធដែលតុលាការជាន់ខ្ពស់ត្រូវសម្រេចភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃសាលក្រម ឬ សាលដីការបស់តុលាការដើម ដោយផ្អែកលើធនធានជាឯកសារសម្រាប់ធ្វើការសម្រេចដែលបានដាក់មក។
  →ការដាក់ធនធានឯកសារថ្មីសម្រាប់ធ្វើការសម្រេចនៅក្នុងតុលាការជាន់ខ្ពស់ត្រូវបានកម្រិត។

- ការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ជាការជំនុំជម្រះបន្ត (យោងម.272 ក.2 , ម.274)
  →សាលាឧទ្ធរណ៍ត្រូវសម្រេចអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវរបស់សាលក្រមនៃការជំនុំជម្រះលើកទី១ ដោយផ្អែកលើធនធានឯសារដែលបានដាក់នៅក្នុងការជំនុំជម្រះលើកទី១ និង ធនធានឯកសារបានដាក់នៅក្នុងការជំនុំជម្រះឧទ្ធរណ៍។

## « ការជំនុំជម្រះតាមក្រោយ »

ភស្តុតាង ជាអាទិ៍ + ភស្តុតាង ជាអាទិ៍ → *<u>សម្រេច</u>* → លិខិតសាលដីកា

ការជំនុំជម្រះលើកទី១

ការជំនុំជម្រះបណ្តឹងឧបាស្រ័យ

ការជំនុំជម្រះបណ្តឹងឧបាស្រ័យ

## « ការជំនុំជម្រះបន្ត »

ភស្តុតាង ជាអាទិ៍ + ភស្តុតាង ជាអាទិ៍ → *<u>សម្រេច</u>* → លិខិតសាលដីកា

ការជំនុំជម្រះលើកទី១

ការជំនុំជម្រះបណ្តឹងឧបាស្រ័យ

ការជំនុំជម្រះបណ្តឹងឧបាស្រ័យ

## 2 ការជំនុំជម្រះលើអង្គច្បាប់ (ម.284)

- 「ការជំនុំជម្រះលើអង្គច្បាប់ 」គឺជា ប្រព័ន្ធដែលតុលាការនៃបណ្ដឹងឧបាស្រ័យជំនុំជម្រះតែលើបញ្ហាច្បាប់ប៉ុណ្ណោះ។
  →មិនជំនុំជម្រះអំពីបញ្ហាអង្គហេតុទេ។

- ការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ គឺជាការជំនុំជម្រះលើអង្គហេតុ
  →ជំនុំជម្រះអំពីរឿងក្ដីទាំងលើបញ្ហាអង្គហេតុ និង បញ្ហាអង្គច្បាប់។

# « ការជំនុំជម្រះលើអង្គច្បាប់ »




# « ការជំនុំជម្រះលើអង្គហេតុ »



## 【លំហូរនៃការវិនិច្ឆ័យ】

ការវិនិច្ឆ័យលើឯកសារ



- ជាបឋម គឺពិនិត្យមើលតែលើឯកសារផ្សេងៗដូចជា ពាក្យបណ្ដឹងសាទុក្ខ លិខិតបញ្ជាក់មូលហេតុ ដោយមិនបើកការទាញហេតុផលដោយផ្ទាល់មាត់
- តុលាការអាចបង្គាប់ឲ្យដាក់ឯកសារត្រៀមបាន (ម.293)។



លទ្ធផលនៃការវិនិច្ឆ័យលើឯកសារ…

- យល់ឃើញថាបណ្ដឹងសាទុក្ខផ្ទុយច្បាប់
  - →ដីកាសម្រេចលើកចោលបណ្ដឹងសាទុក្ខ (ម.290)
- យល់ឃើញថាគ្មានមូលហេតុធ្វើបណ្ដឹងសាទុក្ខ
  - →សាលដីកាច្រានចោលបណ្ដឹងសាទុក្ខ (ម.294)



- ប្រសិនបើមិនអាចយល់ច្បាស់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ដោយគ្រាន់តែវិនិច្ឆ័យលើឯកសារបានទេ តុលាការបើកការទាញហេតុផ្ទាល់មាត់ ហើយវិនិច្ឆ័យ។

ការវិនិច្ឆ័យដោយទាញហេតុផលផ្ទាល់មាត់



លទ្ធផលនៃការវិនិច្ឆ័យលើឯកសារ…

- ទទួលស្គាល់ថាគ្មានមូលហេតុធ្វើបណ្តឹងសាទុក្ខ
  - →សាលដីកាច្រានចោលបណ្តឹងសាទុក្ខ
    (យោង ម.294)

- ទទួលស្គាល់ថាមានមូលហេតុធ្វើបណ្តឹងសាទុក្ខ
  - →បដិសេធចោលហើយបញ្ជូនទៅតុលាការដើម(ម.299 ក.1)
    បដិសេធចោលហើយផ្ទេរទៅតុលាការផ្សេង
    (ម.299 ក.1)
    បដិសេធចោលហើយវិនិច្ឆ័យខ្លួនឯង
    (ម.300)

លិខិត
សាលដីកា

【ចំណុចត្រូវប្រុងប្រយ័ត្នចំពោះការវិនិច្ឆ័យនៃការជំនុំជម្រះបណ្តឹងសាទុក្ខ】

▪បណ្តឹងសាទុក្ខត្រូវយកមកអនុវត្តដូចគ្នាចំពោះនីតិវិធីនៃការជំនុំជម្រះលើកទី១ និង ការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ លើកលែងតែមានបទបញ្ញត្តិពិសេស ( ម.286, ម.286▪ម.273)។

→ ការជំនុំជម្រះបណ្តឹងសាទុក្ខត្រូវបានកម្រិតដោយសារជាតុនៃការជំនុំជម្រះពេលក្រោយ និងការជំនុំជម្រះលើអង្គច្បាប់។

× ម.272 ក.2 (សេចក្តីថ្លៃការណ៍អំពីលទ្ធផលនៃការទាញហេតុផលផ្ទាល់មាត់)

→បញ្ញត្តិជាមូលដ្ឋាននៃប្រព័ន្ធជំនុំជម្រះបន្ត។

× ម.276 (បណ្តឹងតប)

→ជាការជំនុំជម្រះដោយយកអង្គហេតុជាមូលដ្ឋាន។

× ម.84 (ការផ្លាស់ប្តូរកម្មវត្ថុបណ្តឹង)

→ ជាការជំនុំជម្រះដោយយកអង្គហេតុជាមូលដ្ឋាន។

○ ម.217 (ការដកពាក្យបណ្តឹង)

→មិនចាំបាច់វិនិច្ឆ័យអំពីអង្គហេតុ។

- ការទាញហេតុផលផ្ទាល់មាត់ត្រូវធ្វើក្នុងកម្រិតដែលភាគីទាមទារឲ្យកែប្រែសាលក្រម ឬ សាលដីកាដើម (ម. 286▪ម. 272 ក.1)។
  →ក្នុងករណីជាក់លាក់ណាមួយ ការទាញហេតុផលផ្ទាល់មាត់មិនចាំបាច់បើកក៏បានដែរ (ម.290 ,ម.294)។

- ការស្រាវជ្រាវរបស់តុលាការ ត្រូវធ្វើក្នុងកម្រិតនៃឧបាស្រ័យដោយផ្អែកលើមូលហេតុនៃបណ្ដឹងសាទុក្ខ (ម.295)។
  →ចំណុចដែលត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិមិនត្រូវយកមកអនុវត្តនោះទេ (ម.297) ហេតុនេះ តុលាការត្រូវស្រាវជ្រាវទោះបីជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ។

*(៤)* អំឡុងពេលបណ្ដឹងសាទុក្ខ ដែរឬទេ?
ផ្ទុយនឹងសមត្ថកិច្ចផ្ដាច់មុខ ដែរឬទេ? ជាអាទិ៍

- តុលាការនៃបណ្តឹងសាទុក្ខទទួលចំណាងចំពោះអង្គហេតុដែលបានចូលជាស្ថាពរដោយត្រឹមត្រូវតាមច្បាប់ក្នុងសាលដីកាដើម ឬ សាលក្រមដើម (ម.296 ក.1)។

  →ភាគីមិនអាចអះអាងនៅតុលាការនៃបណ្តឹងសាទុក្ខ អំពីអង្គហេតុថ្មីដែលមិនបានដាក់នៅក្នុងតុលាការនៃបណ្តឹងឧទ្ធរណ៍បានឡើយ។

  ភាគីក៏មិនអាចស្នើសុំដាក់ភស្តុតាងថ្មី និង សាក្សីថ្មីបានទេ ដោយសារតែវាជាការបញ្ជាក់អំពីអង្គហេតុថ្មី។

  → តុលាការនៃបណ្តឹងសាទុក្ខមិនទទួលចំណាងលើអង្គហេតុដែលបានចូលជាស្ថាពរក្នុងតុលាការនៃបណ្តឹងឧទ្ធរណ៍ ចំពោះចំណុចដែលត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិឡើយ។

  ដើម្បីបញ្ជាក់អំពីអង្គហេតុថ្មីបែបនេះ តុលាការអាចស្រាវជ្រាវភស្តុតាង តាមវិធីសមរម្យបាន។

- បញ្ហារដ្ឋធម្មនុញ្ញ ត្រូវវិនិច្ឆ័យដោយក្រុមប្រឹក្សាធម្មនុញ្ញ (រដ្ឋធម្មនុញ្ញ ម.141 ក.1, ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ម.18 ក.1 , ម.19 ក.3)

**រដ្ឋធម្មនុញ្ញ មាត្រា 141**

1 ក្រោយពីច្បាប់ណាមួយ ត្រូវបានប្រកាសឲ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រចំនួនមួយភាគដប់ ឬ តុលាការ អាចសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ អំពីធម្មនុញ្ញភាពនៃច្បាប់នេះ។

**ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ មាត្រា 18**

1 ក្រោយពីច្បាប់ណាមួយ ត្រូវបានប្រកាសឲ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រចំនួនមួយភាគដប់ ឬ តុលាការ អាចសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ អំពីធម្មនុញ្ញភាពនៃច្បាប់នេះ។

**មាត្រា 19**

3 តុលាការកំពូលត្រូវចាត់ការពិនិត្យនិងប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១៥ថ្ងៃ យ៉ាងយូរ លើកលែងតែតុលាការកំពូលយល់ឃើញថា ពាក្យប្តឹងតវ៉ានោះមិនអាចទទួលបាន។

# ៩ ការសម្រេចនៃការជំនុំជម្រះ
# បណ្តឹងសាទុក្ខ

【ប្រភេទ】

1 ដីកាសម្រេចលើកចោលពាក្យបណ្តឹងសាទុក្ខ(ម.286･ម.266 ក.2)

2 ដីកាសម្រេចលើកចោលបណ្តឹងសាទុក្ខ

1)មិនអាចកែតម្រូវចំណុចខ្វះខាត (ម.290 ចំ.ក)

2)មិនដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ (ម.290 ចំ.ខ ខាងដើម)

3)មិនកែតម្រូវចំណុចខ្វះខាតក្នុងលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ (ម.290 ចំ.ខ ខាងក្រោយ)

3 សាលដីកាច្រានចោលបណ្តឹងសាទុក្ខ

1) មិនឆ្លងកាត់ការទាញហេតុផលផ្ទាល់មាត់ (ម.294)

2) ឆ្លងកាត់ការទាញហេតុផលផ្ទាល់មាត់ (យោង ម.294)

4 សាលដីកាបដិសេធចោល

1) បញ្ជូនវិញ(ម.299 ក.1)

2) ផ្ទេរ (ម.299 ក.1)

3) វិនិច្ឆ័យខ្លួនឯង (ម.300)

# 【ការសម្រេចនៃការជំនុំជម្រះបណ្ដឹងសាទុក្ខ (លំហូរចម្បង)】



## ៩ ការសម្រេចរបស់តុលាការនៃបណ្ដឹងសាទុក្ខ



## ៩ ការសម្រេចរបស់តុលាការនៃបណ្ដឹងសាទុក្ខ

គ្រាន់តែពិនិត្យឯកសារ តើមូលហេតុនៃបណ្ដឹងសាទុក្ខអាចទទួលស្គាល់បាន ដែរឬទេ?

YES → 3–1 ច្រានចោលបណ្ដឹងសាទុក្ខ (សាលដីកា) ម.294

NO ↓

(ក្រោយពេលបើកការទាញហេតុផលផ្ទាល់មាត់ និងវិនិច្ឆ័យ) តើមូលហេតុនៃបណ្ដឹងសាទុក្ខអាចទទួលស្គាល់បាន ដែរឬទេ?

NO → 3–2 ច្រានចោលបណ្ដឹងសាទុក្ខ (សាលដីកា) យោង ម.294

YES ↓

តើអាចសម្រេចបាន ដោយផ្អែកលើអង្គហេតុស្ថាពររបស់តុលាការដើមដែរឬទេ?

NO → 4–1 បដិសេធចោល ហើយបញ្ជូនវិញ (សាលដីកា)
4–2 បដិសេធចោលហើយផ្ទេរ (សាលដីកា)
ម.299 ក.1

YES → 4–3 បដិសេធចោលហើយវិនិច្ឆ័យដោយខ្លួនឯង (សាលដីកា) ម.300 ចំ.ក

# បដិសេធចោលហើយបញ្ជូនត្រឡប់ ／ បដិសេធចោលហើយផ្ទេរទៅតុលាការផ្សេង

(ម.299 ក.1)

មាត្រា 299

1 នៅក្នុងករណីដែលមានមូលហេតុដែលបានកំណត់ក្នុងមាត្រា 284 (មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ) ឬ មាត្រា 285 (មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ) នៃក្រមនេះ តុលាការនៃបណ្តឹងសាទុក្ខត្រូវបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើម ហើយត្រូវបញ្ជូនរឿងក្តីត្រឡប់ទៅតុលាការដើមវិញ ឬ ផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា លើកលែងតែក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា 300 (ការបដិសេធចោល ហើយវិនិច្ឆ័យខ្លួនឯង) នៃក្រមនេះ។

(ឧទាហរណ៍នៃការបដិសេធចោល ហើយបញ្ជូនត្រឡប់)

- ករណីដែលចំនួនចៅក្រមនៃក្រុមប្រឹក្សាជំនុំជម្រះមិនគ្រប់គ្រាន់ បើសិនជាដកចៅក្រមដែលចូលរួមសាលដីកា ឬ សាលក្រមដើមចេញ។

【ការវិនិច្ឆ័យដើម្បីបដិសេធចោលហើយបញ្ជូនត្រឡប់ ／ បដិសេធចោលហើយផ្ទេរទៅតុលាការផ្សេង】

- ត្រូវឆ្លងកាត់ការទាញហេតុផលផ្ទាល់មាត់

→ម.294 គឺជាបញ្ញត្តិលើករណីលើកលែង ហេតុនេះ តុលាការត្រូវបើកការទាញហេតុផលផ្ទាល់មាត់ ដើម្បីបដិសេធចោលសាលក្រមដើម។



【ការវិនិច្ឆ័យក្រោយពីការបដិសេធចោលហើយបញ្ជូនត្រឡប់ ／ បដិសេធចោលហើយផ្ទេរទៅតុលាការផ្សេង】

・តុលាការដែលទទួលការបញ្ជូន ត្រូវបើកការទាញហេតុផលដោយផ្ទាល់មាត់ ហើយវិនិច្ឆ័យ (ម.299 ក.2)។

ការទាញហេតុផលផ្ទាល់មាត់នេះ មានសារជាតុជាការបន្តការទាញហេតុផលផ្ទាល់មាត់មុន។

→អាចធ្វើគ្រប់សកម្មភាពបណ្តឹងទាំងអស់ ដែលតុលាការថ្នាក់នេះអាចធ្វើបាន។

*（ឧ） ការផ្លាស់ប្តូរកម្មវត្ថុបណ្តឹង បណ្តឹងតប និងការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន ជាអាទិ៍*

→អាចវិនិច្ឆ័យរឿងក្តីទាំងមូលបាន ដោយមិនកម្រិតត្រឹមចំណុចដែលជាមូលហេតុនៃការបដិសេធចោលទេ។

→មិនមានចំណងជាមួយការសម្រេចនៅក្នុងសាលដីកាសាលឧទ្ធរណ៍មុនទេ។



- ចៅក្រមដែលចូលរួមក្នុលសាលក្រម ឬ សាលដីកាដើមមិនអាច ចូលរួមវិនិច្ឆ័យចំពោះការបញ្ជូនត្រឡប់ទេ (ម.299 ក.3)។
  →ត្រូវប្តូរចៅក្រមថ្មី និង ទាញហេតុផលជាថ្មី (ម.185)។
- សេចក្តីវិនិច្ឆ័យលើអង្គហេតុ និង អង្គច្បាប់ ដែលតុលាការនៃបណ្តឹងសាទុក្ខយកជាមូលហេតុនៃការបដិសេធចោល មានចំណងទៅលើតុលាការដែលទទួលការបញ្ជូន (ម.299 ក.2)។

《ទស្សនៈទូទៅនៅជប៉ុន》

- 「ការវិនិច្ឆ័យអង្គហេតុ」 គឺជាការវិនិច្ឆ័យអំពីអង្គហេតុដែលជាចំណុចដែលតុលាការនៃបណ្តឹងសាទុក្ខអាចវិនិច្ឆ័យបានដោយខ្លួនឯង ដូចគ្នាទៅនឹងចំណុចស្រាវជ្រាវដោយឆន្ទានុសិទ្ធិ។
  × ការវិនិច្ឆ័យអំពីអង្គហេតុនៃអង្គសេចក្តី
  →ការវិនិច្ឆ័យអំពីអង្គសេចក្តី គឺជាមុខងារនៃការវិនិច្ឆ័យអង្គហេតុ។
- 「ការវិនិច្ឆ័យអង្គច្បាប់」 គឺជាការវិនិច្ឆ័យអំពីការអនុវត្ត ឬ មិនអនុវត្តការបកស្រាយច្បាប់។

## 【អានុភាពចងនៃសាលដីកាបដិសេធចោល】

《 ទស្សនៈទូទៅនៅជប៉ុន 》

- ទោះបីជាការជំនុំជម្រះនៃបណ្តឹងសាទុក្ខបានសម្រេចអំពីអង្គច្បាប់ ដោយយកអង្គហេតុស្ថាពររបស់សាលាឧទ្ធរណ៍ជាមូលដ្ឋានក៏ដោយ ក៏អង្គហេតុនោះ មិនចងតុលាការដែលបានទទួលការបញ្ជូនឡើយ។

  → តុលាការដែលបានទទួលការបញ្ជូនអាចទទួលស្គាល់អង្គហេតុខុសពីសាលាឧទ្ធរណ៍មុន ដោយមិនផ្អែកលើភស្តុតាងថ្មីបាន។




តុលាការដែលបានទទួលការបញ្ជូនមិនមានចំណងចំពោះអង្គហេតុនេះទេ។

《 ទស្សនៈទូទៅនៅជប៉ុន 》

- អានុភាពចងមានតែទៅលើការសម្រេចផ្ទុយដែលមានកំហុស ក្នុងនាមជាមូលហេតុនៃការបដិសេធចោល។

(२) *ករណីការជំនុំជម្រះនៃបណ្តឹងសាទុក្ខបានសម្រេចបដិសេធចោលសាលក្រម ឬ សាលដីកាដើម ដោយយកមូលហេតុថា* 「សាលក្រម ឬ សាលដីកាដើមមានកំហុសក្នុងការបកស្រាយ A ហើយអនុវត្ត (ផ្នែកដែលសម្រេចផ្ទុយ) ប៉ុន្តែ ការបកស្រាយ B ទើបត្រឹមត្រូវ ( ផ្នែកដែលសម្រេចស្រប)។」

→តុលាការដែលបានទទួលការបញ្ជូន

× ការបកស្រាយជា 「A」( ផ្នែកដែលសម្រេចផ្ទុយ )

○ ការបកស្រាយ「B」( ផ្នែកដែលគួរសម្រេចតាម)

○ ការបកស្រាយ「C」(ផ្នែកដែលមិនបានលើកឡើងក្នុងការវិនិច្ឆ័យបណ្តឹងសាទុក្ខ

# (ឧទាហរណ៍) បណ្តឹងទាមទារឲ្យប្រគល់ប្រាក់ដែរផ្ទេរចូលខុស



# *(ឧទាហរណ៍)* បណ្ដឹងទាមទារឲ្យប្រគល់ប្រាក់ដែរផ្ទេរចូលខុស



# (ឧទាហរណ៍) បណ្តឹងទាមទារឲ្យប្រគល់ប្រាក់ដែរផ្ទេរចូលខុស

សាលដីកានៃបណ្តឹងឧទ្ធរណ៍

【សំអាងហេតុ】
អ្នកតម្កល់ប្រាក់(បុគ្គលដែលមានសិទ្ធិទាមទារឲ្យប្រគល់ប្រាក់ដែលផ្ទេរខុសចំពោះ BANK2 ) គឺជា A ហេតុនេះ B មិនអាចទាមទារឲ្យ BANK2 ប្រគល់ទេ។

↓ ប្តឹងសាទុក្ខ

ផ្នែកនៃការសម្រេចផ្ទុយ

សាលដីកានៃបណ្តឹងសាទុក្ខ

【សំអាងហេតុ】
1） អ្នកតម្កល់ប្រាក់ មិនមែនជា A ទេ។
2） អ្នកតម្កល់ប្រាក់ គឺជា B។ ប៉ុន្តែ ការទាមទារឲ្យប្រគល់របស់ B គឺជាការប្រើប្រាស់សិទ្ធិដោយបំពាន ករណីនេះតុលាការយល់ឃើញថា B មិនអាចទាមទារឲ្យប្រគល់ចំពោះ BANK2 ទេ។

↓ បញ្ជូនត្រឡប់

ផ្នែកដែលគួរសម្រេចតាម

មិនអាចសម្រេចផ្ទុយនឹងផ្នែកនៃការសម្រេចផ្ទុយដែលមានខ្លឹមសារថា「អ្នកតម្កល់ប្រាក់មិនមានជា A ទេ។」 (ហេតុផលទី1 នៃសាលដីកាបណ្តឹងសាទុក្ខ)។

សាលដីកាបញ្ជូនត្រឡប់

【សំអាងហេតុ】

× អ្នកតម្កល់ប្រាក់ជា A។

○ អ្នកតម្កល់ប្រាក់ជា B តែការទាមទារឲ្យប្រគល់វិញជាការប្រើប្រាស់សិទ្ធិដោយបំពាន។

○ អ្នកតម្កល់ប្រាក់ជា B តែការទាមទារឲ្យប្រគល់វិញគឺផ្ទុយនឹងគោលការណ៍សុចរិតភាព។

ផ្នែកដែលគួរតែសម្រេចតាម(សំអាងហេតុទី2នៃសាលដីកាវិនិច្ឆ័យបណ្តឹងសាទុក្ខ) មិនត្រូវគោរពនោះទេ។

→អាចយកតាមគំនិតដែលមិនបានលើកឡើងក្នុងសាលដីកានៃការវិនិច្ឆ័យបណ្តឹងសាទុក្ខក៏បានដែរ។

# 【បណ្ដឹងសាទុក្ខចំពោះសាលាឧទ្ធរណ៍ដែលបានទទួលការបញ្ជូនត្រឡប់ (បណ្ដឹងសាទុក្ខលើកទី2)】



- ភាគីអាចប្តឹងសាទុក្ខបាន ប្រសិនបើមិនសុខចិត្តនឹងសាលដីកានៃតុលាការដែលបានទទួលការបញ្ជូនត្រឡប់
- មូលហេតុនៃបណ្តឹងសាទុក្ខ និង នីតិវិធីបណ្តឹងសាទុក្ខ ជាអាទិ៍ គឺធ្វើតាមបណ្តឹងសាទុក្ខទូទៅ។
- អានុភាពចងនៃសាលដីកាបដិសេធចោលរបស់តុលាការនៃបណ្តឹងសាទុក្ខលើកដំបូង (តុលាការនៃបណ្តឹងសាទុក្ខលើកទី១) ក៏មានទៅលើតុលាការនៃបណ្តឹងសាទុក្ខលើកក្រោយ (តុលាការនៃបណ្តឹងសាទុក្ខលើកទី២) ផងដែរ។

→ប៉ុន្តែ ប្រសិនបើនៅក្នុងការវិនិច្ឆ័យរបស់តុលាការដែលបានបញ្ជូនត្រឡប់ មានកែប្រែទំនាក់ទំនងអង្គហេតុ និង ការអនុវត្តបញ្ញត្តិច្បាប់ អានុភាពចងនៃសាលដីកាបដិសេធចោលនៃការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី១ គ្មានទៅលើការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី២ទេ។

# ការបដិសេធចោល ហើយវិនិច្ឆ័យខ្លួនឯង
(ម.300)

មាត្រា 300

ក តុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើម ដោយយកមូលហេតុថា តុលាការនៃការជំនុំជម្រះដើមមានកំហុសក្នុងការអនុវត្តវេជ្ជធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត ចំពោះអង្គហេតុ ដែលបានចូលជាស្ថាពរ ហើយតុលាការនៃបណ្តឹងសាទុក្ខអាចសម្រេចសេចក្តីអំពីរឿងក្តីនោះ ដោយផ្អែកលើអង្គហេតុនេះបាន។

ខ តុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើម ដោយយកមូលហេតុថា រឿងក្តីនោះមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់តុលាការ។

【ចំណាំ】

- ក្នុងករណីដែលមានភាពចាំបាច់ត្រូវស្រាវជ្រាវភស្តុតាងបន្ថែមពាក់ព័ន្ធនឹងទំនាក់ទំនងអង្គហេតុ តុលាការមិនអាចបដិសេធចោលហើយវិនិច្ឆ័យខ្លួនឯងទេ ប៉ុន្តែត្រូវបដិសេធចោលហើយបញ្ជូនត្រឡប់វិញ។

## 【ប្រភេទចម្លងៗនៃការបដិសេធចោល ហើយវិនិច្ឆ័យខ្លួនឯង】

## 1 លើកចោលបណ្តឹងឧទ្ធរណ៍

ករណីតុលាការកំពូលបដិសេធចោលសាលដីកាដើមដែលបានចេញដោយមើលរំលង លើភាពគ្មានលក្ខខណ្ឌស្របច្បាប់សម្រាប់ធ្វើបណ្តឹងឧទ្ធរណ៍។

(ឧ) បណ្តឹងទាមទារឲ្យសងប្រាក់កម្ចី (ខាងក្រោមដូចគ្នា)

| សាលដីកានៃការជំនុំជម្រះឧទ្ធរណ៍ជាក់ស្តែង | សាលដីកានៃនៃការជំនុំជម្រះឧទ្ធរណ៍ដែលត្រូវតែចេញ |
|---|---|
| 「ច្រានចោលបណ្តឹងឧទ្ធរណ៍នៃរឿងក្តីនេះ។」 | 「លើកចោលបណ្តឹងឧទ្ធរណ៍នៃរឿងក្តីនេះ។」 |

## 2 ប្រានចោលបណ្តឹងឧទ្ធរណ៍

ករណីតុលាការកំពូលបដិសេធចោលសាលដីកាដើមដែលបានសម្រេចដោយខ្លួនឯង ដោយលុបចោលសាលក្រមជនុំជម្រះលើកទី១ ទាំងដើមឡើយត្រូវប្រានចោលបណ្តឹងឧទ្ធរណ៍

សាលដីកានៃបណ្តឹងឧទ្ធរណ៍ជាក់ស្តែង

「 លុបចោលសាលក្រមជនុំជម្រះលើកទី១ ។
បង្គាប់ឲ្យចុងបណ្តឹងឧទ្ធរណ៍បង់ប្រាក់ចំនួន.......ទៅឲ្យដើមបណ្តឹងឧទ្ធរណ៍។」

សាលដីកានៃបណ្តឹងឧទ្ធរណ៍ដែលត្រូវតែចេញ

「ប្រានចោលបណ្តឹងឧទ្ធរណ៍នៃរឿងក្តីនេះ។」

## 3 លុបចោលសាលក្រមជំនុំជម្រះលើកទី១ ហើយច្រានចោលការទាមទារ

ករណីតុលាការកំពូលបានបដិសេធចោលសាលដីការដើមរបស់សាលាឧទ្ធរណ៍ដែលច្រានចោលការទាមទារ លើសាលក្រមជំនុំជម្រះលើកទី១ ដែលដើមឡើយត្រូវច្រានចោលការទាមទារ ប៉ុន្តែតុលាការនៃការជំនុំជម្រះលើកទី១ បានចេញសាលក្រម

សាលក្រមនៃការជំនុំជម្រះលើកទី១ដាក់ស្តែង

「 បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន....... ទៅឲ្យដើមចោទ។」

សាលដីកានៃបណ្តឹងឧទ្ធរណ៍ដាក់ស្តែង

「ច្រានចោលបណ្តឹងឧទ្ធរណ៍នៃរឿងក្តីនេះ។」

សាលក្រមនៃការជំនុំជម្រះលើកទី១ត្រូវចេញ

「ច្រានចោលការទាមទាររបស់ដើមចោទ។」

# 4 លុបចោលសាលក្រមជំនុំជម្រះលើកទី១ ហើយទទួលស្គាល់ការទាមទារ ករណីតុលាការកំពូលបានបដិសេធចោលសាលដីកាដើមដែលលើកចោលបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមជំនុំជម្រះលើកទី១ ដែលសាលាជំនុំជម្រះលើកទី១គួរតែទទួលស្គាល់ការទាមទារ។

សាលក្រមនៃការជំនុំជម្រះលើកទី១ដាក់ស្តែង

「ច្រានចោលការទាមទាររបស់ដើមចោទ។」

សាលដីកានៃបណ្តឹងឧទ្ធរណ៍ដាក់ស្តែង

「ច្រានចោលបណ្តឹងឧទ្ធរណ៍នៃរឿងក្តីនេះ។」

សាលក្រមនៃការជំនុំជម្រះលើកទី១ត្រូវចេញ

「បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន.....ទៅឲ្យដើមចោទ។」

5 លុបចោលសាលក្រមជំនុំជម្រះលើកទី១ ហើយលើកចោលបណ្ដឹង ករណីតុលាការកំពូលបដិសេធចោលសាលដីកាដើមដែលសាលាឧទ្ធរណ៍បានច្រានចោលបណ្ដឹងឧទ្ធរណ៍ លើសាលក្រមជំនុំជម្រះលើកទី១ ដែលបានមើលរំលងលើភាពគ្មានលក្ខខណ្ឌនៃបណ្ដឹង។

សាលក្រមនៃការជំនុំជម្រះលើកទី១ ដាក់ស្ដែង

「បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន......ឲ្យទៅដើមចោទ។」

សាលដីកានៃបណ្ដឹងឧទ្ធរណ៍ដាក់ស្ដែង

「ច្រានចោលបណ្ដឹងឧទ្ធរណ៍នៃរឿងក្ដីនេះ។」

សាលក្រមនៃការជំនុំជម្រះលើកទី១ ត្រូវចេញ

「លើកចោលបណ្ដឹង។」

## 6 លុបចោលសាក្រមជំនុំជម្រះលើកទី១ ហើយបញ្ជូនត្រឡប់ទៅការជំនុំជម្រះលើកទី១

ករណីតុលាការកំពូលបានបដិសេធចោលសាលដីកាដើមដែលច្រានចោលបណ្តឹងឧទ្ធរណ៍លើសាលក្រមនៃការជំនុំជម្រះលើកទី១ ដែលបានមើលរំលងអំពីលក្ខខណ្ឌនៃបណ្តឹង ហើយបានច្រានចោលដោយមិនស្របច្បាប់

សាលក្រមនៃការជំនុំជម្រះលើកទី១ដាក់ស្តែង

「លើកចោលបណ្តឹង។」

សាលដីកានៃបណ្តឹងឧទ្ធរណ៍ដាក់ស្តែង

「ច្រានចោលបណ្តឹងឧទ្ធរណ៍នៃរឿងក្តីនេះ។」

សាលក្រមនៃការជំនុំជម្រះលើកទី១ត្រូវចេញ

「បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន....ទៅឲ្យដើមចោទ។」 ឬ 「ច្រានចោលការទាមទាររបស់ដើមចោទ」

# លើកចោលពាក្យបណ្ដឹងសាទុក្ខ (៤)

## ដីកាសម្រេច

【សេចក្ដីសម្រេចបញ្ចប់】

「លើកចោលពាក្យបណ្ដឹងសាទុក្ខនៃរឿងក្ដីនេះ។」

ដើមបណ្ដឹងសាទុក្ខមិនអាចប្ដឹងជំទាស់បានទេ (យោង ម.259 ក.2)។

# លើកចោលបណ្ដឹងសាទុក្ខ (២)

## ដីកាសម្រេច

【សេចក្ដីសម្រេចបញ្ចប់】

「លើកចោលបណ្ដឹងសាទុក្ខនៃរឿងក្ដីនេះ។」

ដើមបណ្ដឹងសាទុក្ខមិនអាចប្ដឹងជំទាស់បានទេ (យោង ម.259 ក.2)។

# ច្រានចោលបណ្តឹងសាទុក្ខ (៤)

## សាលដីកា

【សេចក្តីសម្រេចបញ្ចប់】

「ច្រានចោលបណ្តឹងសាទុក្ខនៃរឿងក្តីនេះ។」

# បដិសេធចោលហើយបញ្ជូនត្រឡប់វិញ (២)

## សាលដីកា

【សេចក្តីសម្រេចបញ្ចប់】

「1 បដិសេធចោលសាលដីកាដើម។

2 បញ្ជូនត្រឡប់រឿងក្តីនេះទៅសាលាឧទ្ធរណ៍ភ្នំពេញ។」

# បដិសេធចោលហើយផ្ទេរទៅតុលាការផ្សេង (២)

**សាលដីកា**

【សេចក្ដីសម្រេចបញ្ចប់】

「1 បដិសេធចោលសាលដីកាដើម។

2 ផ្ទេររឿងក្ដីនេះទៅសាលាឧទ្ធរណ៍....។」

※ករណីបើមានបង្កើតសាលាឧទ្ធរណ៍ផ្សេងក្រៅពីរាជធានីភ្នំពេញ។

# បដិសេធចោលហើយវិនិច្ឆ័យខ្លួនឯង (២)

## សាលដីកា

【សេចក្តីសម្រេចបញ្ចប់】

「1 បដិសេធចោលសាលដីកាដើម។

2 ច្រានចោលបណ្តឹងឧទ្ធរណ៍នៃរឿងក្តីនេះ។」

# បដិសេធចោលហើយវិនិច្ឆ័យខ្លួនឯង(២)

## សាលដីកា

【សេចក្ដីសម្រេចបញ្ចប់】

「1　បដិសេធចោលសាលដីកាដើម និង លុបចោលសាលក្រមជំនុំជម្រះលើកទី១។

2　បង្គាប់ឲ្យចុងបណ្ដឹងសាទុក្ខបង់ប្រាក់ចំនួន 1000$ និង ការប្រាក់ក្នុងអាត្រា៥%ក្នុងមួយឆ្នាំនៃទឹកប្រាក់ 1000$ គិតចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2018 រហូតដល់សងគ្រប់ឲ្យទៅដើមបណ្ដឹងសាទុក្ខ។」

【ការកម្រិតនៃការបដិសេធចោល】

- ក្នុងករណីបណ្តឹងសាទុក្ខផ្ទោះ តុលាការនៃបណ្តឹងសាទុក្ខមិនអាចបដិសេធចោលសាលក្រមដើមឡើយ ដោយយកមូលហេតុថា ការចូលជាស្ថាពរនៃអង្គហេតុក្នុងសាលក្រមដើមនោះ ផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត (ម.296 ក.2)។

  →បណ្តឹងសាទុក្ខផ្ទោះ គឺធ្វើឡើងដោយគិតថាភាគីទាំងសងខាងមិនមានវិវាទអំពីការទទួលស្គាល់អង្គហេតុ នៅក្នុងសាលក្រមនៃការជំនុំជម្រះលើកទី១។

## ១ ការសម្រេចរបស់តុលាការនៃបណ្តឹងសាទុក្ខ

・ទោះបីជាសំអាងហេតុក្នុងសាលក្រមដើមមិនត្រឹមត្រូវក៏ដោយ ក៏តុលាការនៃបណ្តឹងសាទុក្ខ ត្រូវប្រានចោលនូវបណ្តឹងសាទុក្ខនោះដែរបើយល់ឃើញថា សេចក្តីសម្រេចបញ្ចប់ក្នុងសាលក្រមដើមនោះត្រឹមត្រូវ ដោយផ្អែកលើសំអាងហេតុផ្សេង (ម.286・ម.277 ក.2)។

*(២) បណ្តឹងទាមទារឲ្យបញ្ជាក់អំពីកម្មសិទ្ធិលើដី*

សាលដីកាដើម

【សេចក្តីសម្រេចបញ្ចប់】
ប្រានចោលបណ្តឹងឧទ្ធរណ៍

【សំអាងហេតុ】
កម្មសិទ្ធិលើដីបានផ្ទេរឲ្យទៅចុងចម្លើយ ដោយផ្អែកលើកិច្ចសន្យាលក់ទិញ ហេតុនេះ តុលាការមិនអាចទទួលស្គាល់កម្មសិទ្ធិលើដីនៃរឿងក្តីនេះ ជារបស់ដើមចោទបានទេ។

ការគិតរបស់តុលាការនៃបណ្តឹងសាទុក្ខ

ការទទួលស្គាល់កម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យាលក់ទិញ គឺមិនត្រឹមត្រូវទេ។ កម្មសិទ្ធិលើដីត្រូវពិចារណាដោយផ្អែកលើលទ្ធកម្មដោយអាជ្ញាយុកាល។ ប៉ុន្តែ ទោះបីជាតុលាការផ្អែកលើមូលហេតុមួយណាក៏ដោយ ក៏មិនអាចទទួលស្គាល់កម្មសិទ្ធិលើដីនៃរឿងក្តីនេះជារបស់ដើមចោទដែរ ហេតុនេះ សេចក្តីសម្រេចបញ្ចប់ 「ប្រានចោលបណ្តឹងឧទ្ធរណ៍」គឺត្រឹមត្រូវ។

៩ ការសម្រេចរបស់តុលាការនៃបណ្តឹងសាទុក្ខ

សាលដីកានៃបណ្តឹងសាទុក្ខ

○

【សេចក្តីសម្រេចបញ្ចប់】
ច្រានចោលបណ្តឹងសាទុក្ខ

✕

【សេចក្តីសម្រេចបញ្ចប់】
បដិសេធចោលហើយបញ្ជូនត្រឡប់វិញ

【កំណត់ពេលស្ថាពរនៃសាលដីកាបណ្តឹងសាទុក្ខ】

ស្របពេលជាមួយពេលប្រកាសសាលដីកា

→ចូលជាស្ថាពរស្របពេលការប្រកាសសាលដីកា ដោយសារតែមិនមែនវិធីធ្វើឧបាស្រ័យបាន (យោងម.193 ក.1 ម.286･ម.273 វ.2)។

→ករណីសាលដីកាបដិសេធចោលហើយបញ្ជូនត្រឡប់វិញ ឬសាលដីកាបដិសេធចោល ហើយផ្ទេរទៅតុលាការផ្សេង គឺមិនចូលស្ថាពរស្របពេលប្រកាសទេ ហើយបន្តទៅតុលាការដែលបានទទួលការបញ្ជូននេះ។

# 10 បញ្ហាញូអំពីសាលដីកាជប៉ុន

【រចនាសម្ព័ន្ធចាត់តាំង】

- ចៅក្រមតុលាការកំពូលៈ ប្រធាន 1នាក់, ចៅក្រម 14នាក់
- សាលសវនាការៈ សាលសវនាការធំ 1 សាលសវនាការតូច 3

【ចំនួនបណ្ដឹងសាទុក្ខ(រយៈពេល 1ឆ្នាំ)】

ឆ្នាំ2016 រឿងក្ដីរដ្ឋប្បវេណី 4,268 ករណី
រឿងក្ដីរដ្ឋបាល 921 ករណី
សរុប 5,189 ករណី



【លិខិតសាលដីកាតុលាការកំពូលជប៉ុន】(ឯកសារភ្ជាប់)

បង្ហាញអំពីគម្រូសេចក្តីសម្រេចបញ្ចប់ និង របៀបសរសេរសំអាងហេតុ ជាអាទិ៍ សម្រាប់ជាជំនួយស្មារតី។

1)បដិសេធចោលហើយបញ្ជូនត្រឡប់វិញ

・ឆ្នាំ2014 ខែ3 ថ្ងៃទី14 រឿងក្តីទាមទារបន្ថយបង្គ្រប់ភាគបម្រុង

2)បដិសេធចោលហើយវិនិច្ឆ័យខ្លួនឯង

・ឆ្នាំ2007 ខែ6 ថ្ងៃទី7 រឿងក្តីទាមទារឲ្យប្រគល់ប្រាក់បញ្ញើរមានកាលកំណត់

・ឆ្នាំ2015 ខែ11 ថ្ងៃទី20 រឿងក្តីទាមទារឲ្យបញ្ជាក់មោឃភាពនៃមតកសាសន៍

・ឆ្នាំ2017 ខែ1 ថ្ងៃទី31 រឿងក្តីទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃសុំកូន

※យុត្តិសាស្ត្រជប៉ុន អាចស្វែងរកជាភាសាអង់គ្លេសបាន

http://www.courts.go.jp/app/hanrei_en/search?

## 【លិខិតសាលដីកាតុលាការកំពូលប្រទេសជប៉ុន】(ឯកសាភ្ជាប់)

រចនាសម្ពន្ធ័នៃលិខិតសាលដីកា

1 សេចក្តីសម្រេចបញ្ចប់

2 សំអាងហេតុ

1) ទិដ្ឋភាពនៃរឿងក្តី

2) ការសង្ខេបទំនាក់ទំនងអង្គហេតុដែលស្ថាពរនៅតុលាការដើម

3) ការពន្យល់អំពីសេចក្តីសម្រេចរបស់តុលាការដើម

4) ការមិនអាចទទួលស្គាល់សេចក្តីសម្រេចរបស់តុលាការដើម និងសំអាងហេតុនោះ

- បង្ហាញអំពីការបកស្រាយច្បាប់នៃការជំនុំជម្រះបណ្តឹងសាទុក្ខចំពោះចំណុចវិវាទ
- អនុវត្តការបកស្រាយច្បាប់នោះ ទៅលើទំនាក់ទំនងនៃអង្គហេតុនៃរឿងក្តី

5) សេចក្តីសម្រេចរបស់ការជំនុំជម្រះបណ្តឹងសាទុក្ខ

- ភាពមាន ឬ គ្មានមូលហេតុប្តឹងសាទុក្ខ
- សំអាងហេតុនៃការបដិសេធចោលហើយបញ្ជូនត្រឡប់ ឬ បដិសេធចោល ហើយវិនិច្ឆ័យខ្លួនឯង





# សូមអរគុណ